ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៣៣៥.....សហវ.ប្រក.អគសឌ

# ប្រកាស
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យក្រោមឱវាទនាយកដ្ឋាន នៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ឱ្យស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១**.-

ប្រកាសនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យក្រោមឱវាទនាយកដ្ឋាននៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានានូវប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការបំពេញមុខងារ តួនាទីនិងភារកិច្ចរបស់នាយកដ្ឋាននៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ដូចមានចែងក្នុងអនុក្រឹត្យស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ឱ្យស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២**.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការិយាល័យក្រោមឱវាទនាយកដ្ឋាននៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២
## រចនាសម្ព័ន្ធនាយកដ្ឋាននីមួយៗ

**ប្រការ៣**.-

នាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល មានការិយាល័យក្រោមឱវាទដូចខាងក្រោម៖

១-នាយកដ្ឋានកិច្ចការទូទៅ
- ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ
- ការិយាល័យទំនាក់ទំនងសាធារណៈ
- ការិយាល័យប្រតិបត្តិការផលិតផលឌីជីថល។

២-នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល
- ការិយាល័យវិស្វកម្មប្លាលឌីជីថល
- ការិយាល័យវិទ្យាសាស្ត្រទិន្នន័យ
- ការិយាល័យសន្តិសុខសាយប័រ។

៣-នាយកដ្ឋានកម្មវិធីសេដ្ឋកិច្ចឌីជីថល
- ការិយាល័យបច្ចេកវិទ្យានិងនវានុវត្តន៍
- ការិយាល័យផលិតផលឌីជីថល
- ការិយាល័យគោលនយោបាយនិងកិច្ចការគតិយុត្ត។

ការិយាល័យនីមួយៗក្រោមឱវាទនាយកដ្ឋាននៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ត្រូវដឹកនាំដោយប្រធាន១ (មួយ) រូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។

អង្គការលេខរបស់ការិយាល័យនីមួយៗក្រោមឱវាទនាយកដ្ឋាននៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ការិយាល័យក្រោមឱវាទនាយកដ្ឋាននីមួយៗ
### ផ្នែកទី១
### តួនាទីនិងភារកិច្ចរបស់ការិយាល័យក្រោមឱវាទ នាយកដ្ឋានកិច្ចការទូទៅ

**ប្រការ៤**.-

ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានកិច្ចការទូទៅ ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងដំណើរការឯកសាររដ្ឋបាល និងតម្កល់ឯកសារ
- គ្រប់គ្រងភស្តុភារ កិច្ចការពិធីការ និងសម្របសម្រួលរៀបចំកិច្ចប្រជុំនិងសិក្ខាសាលា
- គ្រប់គ្រងកិច្ចការមន្ត្រីនិងបុគ្គលិក
- គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- សម្របសម្រួលរៀបចំផែនការសកម្មភាព និងគ្រប់គ្រងការរៀបចំនិងការអនុវត្តថវិកា
- សម្របសម្រួលរៀបចំរបាយការណ៍លទ្ធផលនិងសមិទ្ធកម្មការងារជាប្រចាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានកិច្ចការទូទៅ។

**ប្រការ៥**.-

ការិយាល័យទំនាក់ទំនងសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានកិច្ចការទូទៅ ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយនិងបណ្ដាញសង្គម
- គ្រប់គ្រងការរៀបចំអត្ថបទព័ត៌មាន និងជំរុញការផ្សព្វផ្សាយ
- បង្កើតទំនាក់ទំនងជាមួយនឹងអ្នកសារព័ត៌មាន និងជាអ្នកនាំពាក្យរបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
- កសាងនិងពង្រឹងទំនាក់ទំនងក្នុងភាពជាដៃគូជាមួយនឹងភាគីពាក់ព័ន្ធ
- គ្រប់គ្រងនិងសម្របសម្រួលការរៀបចំសិក្ខាសាលា សន្និសីទ ទស្សនកិច្ចសិក្សា និងពិធីផ្សេងៗ
- រៀបចំនិងអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងការផ្លាស់ប្តូរ
- កៀរគរការចូលរួម និងជំរុញការអនុវត្តការប្រើប្រាស់ថ្នាលឬកម្មវិធីសេដ្ឋកិច្ចឌីជីថល
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានកិច្ចការទូទៅ។

**ប្រការ៦**.-

ការិយាល័យប្រតិបត្តិការផលិតផលឌីជីថល បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានកិច្ចការទូទៅ ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការដំឡើងនិងការដាក់ឱ្យដំណើរការប្រើប្រាស់ផលិតផលឌីជីថល
- ផ្ដល់ការគាំទ្រ និងដោះស្រាយបញ្ហាបច្ចេកទេសជាមួយនឹងអ្នកប្រើប្រាស់ផលិតផលឌីជីថល
- រៀបចំនិងចងក្រងសៀវភៅឬឯកសារណែនាំអំពីរបៀបប្រើប្រាស់ផលិតផលឌីជីថល
- គ្រប់គ្រងការផ្លាស់ប្តូរ និងការធ្វើបច្ចុប្បន្នកម្មមុខងារឬលក្ខណសម្បត្តិរបស់ផលិតផលឌីជីថល
- សម្របសម្រួលរៀបចំការបណ្តុះបណ្តាលឬផ្សព្វផ្សាយអំពីការប្រើប្រាស់ផលិតផលឌីជីថល

- ប្រមូលនិងបូកសរុបមតិប្រតិកម្មឆ្លើយតប និងការស្នើសុំពីអ្នកប្រើប្រាស់ផលិតផលឌីជីថល
- គ្រប់គ្រងប្រព័ន្ធជំនួយគាំទ្រ និងចងក្រងឯកសារសម្រាប់រៀបចំប្រព័ន្ធស្វ័យគាំទ្រ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានកិច្ចការទូទៅ។

## ផ្នែកទី២
## តួនាទីនិងភារកិច្ចរបស់ការិយាល័យក្រោមឱវាទ
## នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល

**ប្រការ៧**.-

ការិយាល័យវិស្វកម្មថ្នាលឌីជីថល បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំនិម្មាបនកម្មនិងដំឡើងហេដ្ឋារចនាសម្ព័ន្ធថ្នាលឌីជីថល
- គ្រប់គ្រងសេវូបករណ៍និម្មិតនិងធនធានរក្សាទុកទិន្នន័យ
- គ្រប់គ្រងប្រព័ន្ធគ្រប់គ្រងមូលទិន្នន័យនិងប្រព័ន្ធគ្រប់គ្រងឃ្លាំងទិន្នន័យ
- អភិវឌ្ឍ និងគ្រប់គ្រងថ្នាលឌីជីថលគ្រឹះសម្រាប់កម្មវិធីសេដ្ឋកិច្ចឌីជីថល
- គ្រប់គ្រងការស្តារគ្រោះមហន្តរាយ និងធានានិរន្តរភាពប្រតិបត្តិការថ្នាលឌីជីថល
- គ្រប់គ្រងការធ្វើសន្ធានកម្មនិងការភ្ជាប់ទំនាក់ទំនងជាមួយនឹងប្រព័ន្ធឬថ្នាលឌីជីថលផ្សេងៗ
- ស្រាវជ្រាវអំពីនិន្នាការបច្ចេកវិទ្យាថ្មីៗក្នុងបរិការណ៍តំបន់និងសកល ពាក់ព័ន្ធនឹងថ្នាលឌីជីថលគ្រឹះ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល។

**ប្រការ៨**.-

ការិយាល័យវិទ្យាសាស្ត្រទិន្នន័យ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងការប្រមូល បំប្លែង និងការបញ្ចូលទិន្នន័យក្នុងឃ្លាំងរក្សាទុក
- គ្រប់គ្រងការងារវិភាគទិន្នន័យនិងកំណត់ចេញជាទម្រង់ព័ត៌មានដែលមានអត្ថន័យគ្រប់គ្រាន់
- បង្កើតម៉ូដែលនៃការទស្សន៍ទាយ បង្រៀនម៉ាស៊ីន និងប្រើប្រាស់បញ្ញាសិប្បនិម្មិតវិភាគទិន្នន័យ
- គ្រប់គ្រងការអភិវឌ្ឍរបាយការណ៍ឬផ្ទាំងផ្តល់ព័ត៌មានបែបស្ថិតិ ក្រាប ឬនិន្នាការអនាគត
- ស្រាវជ្រាវ និងប្រើប្រាស់បច្ចេកវិទ្យាប្រព្រឹត្តិកម្មភាសាធម្មជាតិ
- គ្រប់គ្រងនិងពង្រឹងអភិបាលកិច្ចនិងគុណភាពនៃទិន្នន័យ
- គ្រប់គ្រងឯកជនភាពនៃទិន្នន័យនិងពង្រឹងអនុលោមភាពតាមបទប្បញ្ញត្តិនៃការការពារទិន្នន័យ
- សហការនិងសម្របសម្រួលការធ្វើសមកាលកម្មទិន្នន័យជាមួយនឹងកម្មវិធីឬថ្នាលឌីជីថលផ្សេងៗ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល។

**ប្រការ៩**.-

ការិយាល័យសន្តិសុខសាយប័រ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងអភិបាលកិច្ចសន្តិសុខព័ត៌មាន
- រៀបចំនិងអនុវត្តយុទ្ធសាស្ត្រសន្តិសុខសាយប័រ
- រៀបចំនិងពង្រឹងការអនុវត្តគោលការណ៍សុវត្ថិភាពឌីជីថល
- គ្រប់គ្រងឧប្បត្តិហេតុនិងការគំរាមកំហែងផ្នែកសន្តិសុខសាយប័រ
- គ្រប់គ្រងនិងវាយតម្លៃហានិភ័យផ្នែកសន្តិសុខឌីជីថល និងបង្កើតយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ
- រៀបចំឯកសារណែនាំនិងបញ្ជ្រាបការយល់ដឹងផ្នែកសន្តិសុខឌីជីថល
- គ្រប់គ្រងនិងត្រួតពិនិត្យជាប្រចាំលើអត្តសញ្ញាណនៃការចូលប្រើប្រាស់ថ្នាលនិងកម្មវិធីឌីជីថល
- គ្រប់គ្រងការធ្វើតេស្តរកចំណុចចន្លោះប្រហោងនិងការធ្វើសវនកម្មផ្នែកសុវត្ថិភាព
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល។

## ផ្នែកទី៣
## តួនាទីនិងភារកិច្ចរបស់ការិយាល័យក្រោមឱវាទ
## នាយកដ្ឋានកម្មវិធីសេដ្ឋកិច្ចឌីជីថល

**ប្រការ១០.-**

ការិយាល័យបច្ចេកវិទ្យានិងនវានុវត្តន៍ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានកម្មវិធីសេដ្ឋកិច្ចឌីជីថល ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវ វិភាគ និងវាយតម្លៃលើនិន្នាការបច្ចេកវិទ្យាឌីជីថលថ្មីៗ និងផ្តួចផ្តើមយកមកប្រើប្រាស់
- គ្រប់គ្រងការងារស្រាវជ្រាវនិងអភិវឌ្ឍកម្មវិធីសេដ្ឋកិច្ចឌីជីថល
- ផ្តួចផ្តើមនវានុវត្តន៍កម្មវិធីសេដ្ឋកិច្ចឌីជីថល
- កសាងភាពជាដៃគូជាមួយនឹងស្ថាប័នស្រាវជ្រាវនិងបណ្តុះធុរកិច្ចថ្មី និងដៃគូឯកជនពាក់ព័ន្ធនឹងនវានុវត្តន៍
- រៀបចំនិងជំរុញការអនុវត្តយុទ្ធសាស្ត្រនវានុវត្តន៍កម្មវិធីសេដ្ឋកិច្ចឌីជីថល
- លើកកម្ពស់វប្បធម៌នវានុវត្តន៍សម្រាប់កម្មវិធីសេដ្ឋកិច្ចឌីជីថល
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានកម្មវិធីសេដ្ឋកិច្ចឌីជីថល។

**ប្រការ១១.-**

ការិយាល័យផលិតផលឌីជីថល បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានកម្មវិធីសេដ្ឋកិច្ចឌីជីថល ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវនិងផ្តួចផ្តើមក្នុងការបង្កើតផលិតផលឌីជីថលថ្មីៗ
- រៀបចំការស្នើគម្រោងអភិវឌ្ឍផលិតផលឌីជីថល
- គ្រប់គ្រងនិងគាំទ្រគម្រោងអភិវឌ្ឍផលិតផលឌីជីថល
- រៀបចំនូវផែនទីមគ្គុទ្ទេសក៍និងធ្វើអាទិភាវូបនីយកម្មលក្ខណសម្បត្តិនៃផលិតផលឌីជីថល
- គ្រប់គ្រងនិងធានាគុណភាពផលិតផលមុននឹងដាក់ឱ្យប្រើប្រាស់
- គ្រប់គ្រងហានិភ័យនៃការអនុវត្តគម្រោងអភិវឌ្ឍផលិតផលឌីជីថល
- គ្រប់គ្រងកម្មសិទ្ធិបញ្ញាលើផលិតផលឌីជីថលរបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានកម្មវិធីសេដ្ឋកិច្ចឌីជីថល។

**ប្រការ១២.-**

ការិយាល័យគោលនយោបាយនិងកិច្ចការគតិយុត្ត បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានកម្មវិធីសេដ្ឋកិច្ចឌីជីថល ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- សម្របសម្រួលរៀបចំច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល
- គ្រប់គ្រងកិច្ចសន្យានិងកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលក្នុងបរិការណ៍ជាតិ តំបន់ និងសកល
- គ្រប់គ្រងហានិភ័យនិងអនុលោមភាពតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្ត
- គ្រប់គ្រងវិវាទនិងបច្ច័យពីការអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- ស្រាវជ្រាវ និងវិភាគអំពីនិន្នាការ គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងបរិការណ៍តំបន់និងសកល
- សម្របសម្រួលការធ្វើនិយ័តកម្មសកម្មភាពសេដ្ឋកិច្ចឌីជីថលថ្មី
- សហការផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានកម្មវិធីសេដ្ឋកិច្ចឌីជីថល។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៥ កើត ខែភទ្របទ ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ

## នៃប្រកាសលេខ៦៣៥ សហវ.ប្រក.អគសជ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣

## ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យក្រោមឱវាទនាយកដ្ឋាន នៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- **អគ្គនាយក**
  - **អគ្គនាយករង**
    - នាយកដ្ឋានកិច្ចការទូទៅ
      - ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ
      - ការិយាល័យទំនាក់ទំនងសាធារណៈ
      - ការិយាល័យប្រតិបត្តិការផលិតផលឌីជីថល
    - នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល
      - ការិយាល័យវិស្វកម្មផ្ទាលឌីជីថល
      - ការិយាល័យវិទ្យាសាស្ត្រទិន្នន័យ
      - ការិយាល័យសន្តិសុខសាយប័រ
    - នាយកដ្ឋានកម្មវិធីសេដ្ឋកិច្ចឌីជីថល
      - ការិយាល័យបច្ចេកវិទ្យានិងនវានុវត្តន៍
      - ការិយាល័យផលិតផលឌីជីថល
      - ការិយាល័យគោលនយោបាយនិងកិច្ចការគតិយុត្ត